**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃព្រហស្បតិ៍ ៥ កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧*
*រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០២៣*

# សេចក្តីប្រកាសព័ត៌មានស្តីពី
# ពិធីដាក់ដំណើរការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្ម
# តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី ៣

កាលពីវេលាម៉ោង ៩ ព្រឹកថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២៣ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី ៣ ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ដោយមានការចូលរួមយ៉ាងច្រើនកុះករពីក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងសមាគម និងដៃគូអភិវឌ្ឍន៍។

ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន គឺជាការកែទម្រង់ដ៏សំខាន់ និងមុតស្រួចជាកញ្ចប់របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងគោលដៅសម្រួល និងសម្រាលបន្ទុករបស់ធុរជនក្នុងការធ្វើធុរកិច្ចនៅកម្ពុជា។ ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ត្រូវបានដាក់ដំណើរការ ដំណាក់កាលទី ១ នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ ដើម្បីជួយសម្រួលដល់នីតិវិធីនៃការធ្វើធុរកិច្ចទូទៅក្នុងប្រទេសកម្ពុជា ដោយផ្អែកលើគោលការណ៍កាត់បន្ថយនីតិវិធីស្មុគស្មាញ, កាត់បន្ថយចំណាយ និងកាត់បន្ថយថិរវេលា។ ជាមួយនឹងការបន្តពង្រីកវិសាលភាព, ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី ២ ត្រូវបានដាក់ឱ្យដំណើរការ កាលពីថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០២១ ហើយនៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២៣ ដំណាក់កាលទី ៣ ក៏ត្រូវបានដាក់ដំណើរការជាបន្តបន្ទាប់ ។ ដំណើរការនៃប្រព័ន្ធនេះ នៅគ្រប់ដំណាក់កាល ពឹងផ្អែកលើថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data eXchange - CamDX) ជាឆ្អឹងខ្នងនៃការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយទៀត ។ សម្រាប់ការចូលស្នើសុំសេវាណាមួយលើប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន, ធុរជនអាចចូលទៅកាន់គេហទំព័រ **www.registrationservices.gov.kh** ដែលជាគេហទំព័រប្រមូលផ្តុំសេវាទាំងអស់ ដែលបានចូលរួមក្នុងការងារទាំង ៣ ដំណាក់កាល ។ ដោយមានការផ្លាស់ប្តូរទិន្នន័យ តាមរយៈថ្នាល CamDX, ធុរជនដែលបានចុះ

បញ្ជីអាជីវកម្មក្រោយថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ នៅក្នុងថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី ១ (Single Portal) នឹងមិនចាំបាច់វាយបញ្ចូលព័ត៌មានដែលធ្លាប់បានវាយបញ្ចូលហើយក្នុងប្រព័ន្ធ Single Portal ទៀតទេ នៅពេលស្នើសុំសេវាផ្សេងទៀត ក្នុងថ្នាលបច្ចេកវិទ្យាព័ត៌មាន ក្នុងដំណាក់កាលទី ២, ទី ៣ និងដំណាក់កាលបន្តបន្ទាប់ទៀត។ ធុរជនគ្រាន់តែវាយបញ្ចូលលេខសម្គាល់អត្តសញ្ញាណសហគ្រាស (Single ID) នោះព័ត៌មានដែលធ្លាប់ចុះបញ្ជីពីមុន នឹងបង្ហាញលើពាក្យស្នើសុំ ដោយស្វ័យប្រវត្តិ។ ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន គ្របដណ្តប់លើសេវា និងក្រសួង ស្ថាប័ន ជាច្រើន ដូចខាងក្រោម៖

| | ក្រសួង ស្ថាប័ន | ប្រភេទសេវា | រយៈពេលត្រួតពិនិត្យ |
|---|---|---|---|
| **ដំណាក់កាលទី ១ (Single Portal)** | **ក្រសួងមហាផ្ទៃ** | ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណកម្មសម្រាប់ការចូលប្រើប្រាស់ផតថល | N/A |
| | **ក្រសួងពាណិជ្ជកម្ម** | ការបម្រុងទុកនាមករណ៍ | ២ ថ្ងៃនៃថ្ងៃធ្វើការ |
| | | ការចុះបញ្ជីពាណិជ្ជកម្ម | ៣ ថ្ងៃនៃថ្ងៃធ្វើការ |
| | **អគ្គនាយកដ្ឋានពន្ធដារ** | ការចុះបញ្ជីពន្ធដារ | ៤ ថ្ងៃនៃថ្ងៃធ្វើការ |
| | **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | ការធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស | ១ ថ្ងៃនៃថ្ងៃធ្វើការ |
| | **ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** | ការចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | ២០ ថ្ងៃនៃថ្ងៃធ្វើការ |
| **ដំណាក់កាលទី ២** | **ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** | ប្រកាសស្តីពីការបង្កើតសហគ្រាសធុនតូច និងមធ្យម | ពី **១៥ ថ្ងៃនៃថ្ងៃធ្វើការ** ទៅ **៣ ថ្ងៃនៃថ្ងៃធ្វើការ** |
| | **ក្រសួងទេសចរណ៍** | អាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ | ពី **២៨ ថ្ងៃនៃថ្ងៃធ្វើការ** ទៅ **៧ ថ្ងៃនៃថ្ងៃធ្វើការ** |
| | | អាជ្ញាបណ្ណទេសចរណ៍សម្រាប់សណ្ឋាគារ និងសេវាស្នាក់នៅទេសចរណ៍ | |
| | | អាជ្ញាបណ្ណទេសចរណ៍សម្រាប់ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ | |
| | **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** | ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន(ICT) | ពី **៣០ ថ្ងៃនៃថ្ងៃធ្វើការ** ទៅ **៧ ថ្ងៃនៃថ្ងៃធ្វើការ** |
| | | ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យប្រៃសណីយ៍ | |

| | | | |
|---|---|---|---|
| | **និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** | អាជ្ញាបណ្ណអាជីវកម្មទទួលបញ្ចាំ | ពី **៣០ ថ្ងៃនៃថ្ងៃធ្វើការ** ទៅ **៧ ថ្ងៃនៃថ្ងៃធ្វើការ** |
| | | អាជ្ញាបណ្ណអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន | |
| **ដំណាក់កាល ទី ៣** | **ក្រសួងពាណិជ្ជកម្ម** | អាជ្ញាបណ្ណ/លិខិតអនុញ្ញាតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | ពី **១០ ថ្ងៃនៃថ្ងៃធ្វើការ** ទៅ **៥ ថ្ងៃនៃថ្ងៃធ្វើការ** (អាជ្ញាបណ្ណ) |
| | | | ពី **៥ ថ្ងៃនៃថ្ងៃធ្វើការ** ទៅ **៣ ថ្ងៃនៃថ្ងៃធ្វើការ** (លិខិតអនុញ្ញាត) |
| | **ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍** | ប្រកាសបង្កើតសហគ្រាសធុនតូច និងមធ្យម (SMEs) | **៣ ថ្ងៃនៃថ្ងៃធ្វើការ** |
| | **ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ** | លិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹម ឬ បង្កាត់ពូជសត្វ (ខ្នាតមធ្យម និង ខ្នាតធំ) | ពី **៣០ ថ្ងៃនៃថ្ងៃធ្វើការ** ទៅ **១០ ថ្ងៃនៃថ្ងៃធ្វើការ** |
| | **ក្រសួងយុត្តិធម៌** | ព្រឹត្តិបត្រថ្កោលទោស | ១២-២០ ថ្ងៃនៃថ្ងៃធ្វើការ |
| | **ក្រសួងអប់រំ យុវជន និងកីឡា** | អាជ្ញាបណ្ណបើកទារកដ្ឋាន និង/ឬ មត្តេយ្យសិក្សាឯកជន | ពី **៣៥ ថ្ងៃនៃថ្ងៃធ្វើការ** ទៅ **១៥ ថ្ងៃនៃថ្ងៃធ្វើការ** |
| | | អាជ្ញាបណ្ណបើកបឋមសិក្សាឯកជន | |
| | | អាជ្ញាបណ្ណបើកគ្រឹះស្ថានមធ្យមសិក្សាឯកជន | |
| | **ធនាគារជាតិនៃកម្ពុជា** | អាជ្ញាបណ្ណ/លិខិតអនុញ្ញាត សម្រាប់អាជីវកម្មប្តូរប្រាក់ | ពី **៤៥ ថ្ងៃនៃថ្ងៃធ្វើការ** ទៅ **១០-២០ ថ្ងៃនៃថ្ងៃធ្វើការ** |
| | **បេឡាជាតិសន្តិសុខសង្គម** | ការចុះបញ្ជិកាសហគ្រាស-គ្រឹះស្ថាន | ០ ថ្ងៃនៃថ្ងៃធ្វើការ |
| | **និយ័តករធានារ៉ាប់រងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** | ការចុះបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល | ៣ ថ្ងៃនៃថ្ងៃធ្វើការ |
| | **និយ័តករទូរគមនាគមន៍កម្ពុជា** | សេវាចុះឈ្មោះដែនជាតិ .kh | ១០ ថ្ងៃនៃថ្ងៃធ្វើការ |

| | | | |
|---|---|---|---|
| | **និយ័តករគណនេយ្យ និង សវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** | អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈគណនេយ្យ និង សវនកម្ម | ពី **៦០ ថ្ងៃនៃថ្ងៃធ្វើការ** ទៅ **១៥ ថ្ងៃនៃថ្ងៃធ្វើការ** |
| | **អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ** | វិញ្ញាបនបត្រអ្នកទទួលសាងសង់ | ពី **២១ ថ្ងៃនៃថ្ងៃធ្វើការ** ទៅ **១៤ ថ្ងៃនៃថ្ងៃធ្វើការ** |
| | **មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"** | ការចូលជាសមាជិកថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) | ពី **៧ ថ្ងៃនៃថ្ងៃធ្វើការ** ទៅ **៣ ថ្ងៃនៃថ្ងៃធ្វើការ** |

ការដាក់ដំណើរការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន គឺជាសមិទ្ធផលថ្មីមួយទៀតរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយភាពឈ្លៀសវៃ និងប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ សមិទ្ធផលនេះ សបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈររបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងភាពធន់របស់កម្ពុជា ក្នុងដំណើរឆ្ពោះទៅរកសេដ្ឋកិច្ច និងសង្គមឌីជីថល ស្របតាមការដាក់ចេញនូវក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងឯកសារគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥។